ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី កម្មសិក្សាស្រាវជ្រាវនៅធនាគារជាតិនៃកម្ពុជា សម្រាប់ឆ្នាំ២០១៧

ធនាគារជាតិនៃកម្ពុជា មានសេចក្តីសោមនស្សរីករាយសូមជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា ធនាគារជាតិនៃកម្ពុជានឹងផ្តល់ឱកាសកម្មសិក្សាស្រាវជ្រាវដល់និស្សិតចំនួន ៧រូប សម្រាប់រយៈពេលពី ៦ - ១២ខែ នៅឆ្នាំ២០១៧ ខាងមុខ ។ កម្មវិធីកម្មសិក្សាស្រាវជ្រាវនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ឱកាសដល់និស្សិតក្នុងការពង្រឹងសមត្ថភាពនិងទទួលបានបទពិសោធន៍ការងារពាក់ព័ន្ធនឹងការស្រាវជ្រាវក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅធនាគារជាតិនៃកម្ពុជា ។

**លក្ខ័ណទទួលពាក្យ៖**

- មានសញ្ញាបត្របរិញ្ញាបត្រ / អនុបណ្ឌិត / បណ្ឌិត ផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងធនាគារ
- ទទួលបានសញ្ញាបត្រមិនលើសពី ៣ឆ្នាំ ត្រឹមពេលដាក់ពាក្យ
- មានជំនាញភាសាអង់គ្លេសល្អ
- មានសញ្ជាតិខ្មែរ

**ការលើកទឹកចិត្ត៖**

- ធនាគារជាតិនៃកម្ពុជា នឹងផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ

កម្មវិធីកម្មសិក្សាសម្រាប់ឆ្នាំ២០១៧ នេះ នឹងចាប់ផ្តើមនៅខែមីនា ឆ្នាំ២០១៧ ដល់ ខែមីនា ឆ្នាំ២០១៨ ។ សូមបេក្ខជនដែលមានចំណាប់អារម្មណ៍ ផ្ញើសំណុំឯកសារមកកាន់អាសយដ្ឋានទំនាក់ទំនងខាងក្រោម ដែលមានដូចជា៖ ១/- ប្រវត្តិរូបសង្ខេបមានបិទរូបថត (CV) ២/- សញ្ញាបត្រនិងព្រឹត្តិបត្រពិន្ទុ ៣/- និក្ខេបបទ ឬឯកសារស្រាវជ្រាវដែលបានធ្វើ និង ៤/- សំណេរបង្ហាញអំពីចំណាប់អារម្មណ៍ ។

**ទំនាក់ទំនង៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីមែល៖ nbccommunication@nbc.org.kh